ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥៦១ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការអនុវត្តអនុក្រឹត្យលេខ ១៥០ អនក្រ.បក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលអត្រាអាករពិសេសលើមុខទំនិញមួយចំនួន

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០១
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

Collection by VCAT Professional Consultant

- បានឃើញអនុក្រឹត្យលេខ ១៥០ អនក្រ.បក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលអត្រាអាករពិសេសលើមុខទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០១ ស្តីពីការកែសម្រួលអត្រាពន្ធនិងអាករលើទំនិញមួយចំនួន
- បានឃើញប្រកាសលេខ ៣៤១ ប្រក.សហវ.ពដ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៩៧ ស្តីពីអាករពិសេសលើទំនិញនិងសេវាមួយចំនួន
- បានឃើញប្រកាសលេខ ១១៣៣ សហវ.ពដ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការណែនាំអនុវត្តការប្រមូលអាករពិសេសលើទំនិញនិងសេវាមួយចំនួន
- បានឃើញប្រកាសលេខ ១១៤ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីការកែសម្រួលអត្រាអាករពិសេសលើស្រាបៀរផលិតក្នុងស្រុក
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

អនុលោមតាមអនុក្រឹត្យលេខ ១៥០ អនក្រ.បក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ អត្រាអាករពិសេសលើមុខទំនិញបារី និង សុរា (ស្រា) ដែលនាំចូលនិងផលិតក្នុងស្រុក ត្រូវបានកែសម្រួលនិងកំណត់ដូចខាងក្រោម÷

- ២០ ភាគរយ លើមុខទំនិញសុរា ចំនួន ៤៣ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមាន ក្នុងទីតាំងរងលេខ

| | | | | |
|---|---|---|---|---|
| ២២០៤.១០.០០ | ២២០៤.២១.១១ | ២២០៤.២១.១៣ | ២២០៤.២១.១៤ | ២២០៤.២១.២១ |
| ២២០៤.២១.២២ | ២២០៤.២៩.១១ | ២២០៤.២៩.១៣ | ២២០៤.២៩.១៤ | ២២០៤.២៩.២១ |
| ២២០៤.២៩.២២ | ២២០៤.៣០.១០ | ២២០៤.៣០.២០ | ២២០៥.១០.១០ | ២២០៥.១០.២០ |
| ២២០៥.៩០.១០ | ២២០៥.៩០.២០ | ២២០៦.០០.១០ | ២២០៦.០០.២០ | ២២០៦.០០.៣០ |
| ២២០៦.០០.៤០ | ២២០៦.០០.៩១ | ២២០៦.០០.៩៩ | ២២០៧.១០.០០ | ២២០៧.២០.១១ |
| ២២០៧.២០.១៩ | ២២០៧.២០.៩០ | ២២០៨.២០.៥០ | ២២០៨.២០.៩០ | ២២០៨.៣០.០០ |
| ២២០៨.៤០.០០ | ២២០៨.៥០.០០ | ២២០៨.៦០.០០ | ២២០៨.៧០.០០ | ២២០៨.៩០.១០ |
| ២២០៨.៩០.២០ | ២២០៨.៩០.៣០ | ២២០៨.៩០.៤០ | ២២០៨.៩០.៥០ | ២២០៨.៩០.៦០ |

២២០៨.៩០.៧០ ២២០៨.៩០.៨០ និងទីតាំងរងលេខ ២២០៨.៩០.៩០។

- ១៥ ភាគរយ លើមុខទំនិញបារី ចំនួន ០៣ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមាន ក្នុងទីតាំងរងលេខ ២៤០២.២០.១០ ២៤០២.២០.២០ និងទីតាំងរងលេខ ២៤០២.២០.៩០។

**ប្រការ២.-**

មូលដ្ឋានគិតអាករពិសេសលើទំនិញនាំចូលនិងទំនិញផលិតក្នុងស្រុក ត្រូវកំណត់ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

**ប្រការ៣.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.–**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកនៃគ្រប់អគ្គនាយក-ដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- គ្រប់អង្គភាពពន្ធដារ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

Collection by VCAT Professional Consultant